ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ពៅវើយសែនជ័យ

## រយៈពេល ០៣ឆ្នាំ
## (២០១៨ - ២០២១)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ពៅវើយសែនជ័យ |
| ភូមិ | ៖ | ពៅវើយ |
| ឃុំ | ៖ | ពាមបាង |
| ស្រុក | ៖ | ស្ទោង |
| ខេត្ត | ៖ | កំពង់ធំ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ពៅវើយសែនជ័យ

## រយៈពេល ០៣ឆ្នាំ
## (២០១៨ - ២០២១)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ពៅវើយសែនជ័យ |
| ភូមិ | ៖ | ពៅវើយ |
| ឃុំ | ៖ | ពាមបាង |
| ស្រុក | ៖ | ស្ទោង |
| ខេត្ត | ៖ | កំពង់ធំ |

# មាតិកា


**១. ស្ថានភាពទូទៅ** ..... ១

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ..... ១

ក. ប្រជាពលរដ្ឋ ..... ១

ខ. មុខរបរ ..... ២

ខ.១. អ្នកដែលមានមុខរបរនេសាទ ..... ២

ខ.២. អ្នកដែលមានមុខរបរធ្វើអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ ..... ២

**៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ..... ២

ក. ទីតាំង ..... ២

ខ. ដែននេសាទ ..... ៣

ខ.១. ព្រែក ..... ៣

ខ.២. ត្រពាំង ..... ៣

ខ.៣. ស្ទឹង និងអូរ ..... ៣

គ. តំបន់ដែលមានលទ្ធភាពដែលអាចបង្កើតកន្លែងអភិរក្ស ..... ៤

ឃ. ធនធានជលផល ..... ៤

ឃ.១. ប្រភេទត្រី ..... ៤

ឃ.២. ប្រភេទវារីសត្វ ..... ៤

ឃ.៣. ប្រភេទបក្សី ..... ៤

ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ..... ៤

**៤. ការធ្វើនេសាទ** ..... ៤

ក. អ្នកនេសាទ ..... ៥

ខ. ឧបករណ៍នេសាទ ..... ៥

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ..... ៧

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ..... ៧

ក. ទស្សនៈវិស័យ ..... ៧

ខ. គោលបំណង ..... ៧

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៧

គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ..... ៧

គ.២. ផែនការកែលំអដែននេសាទ ..... ១៥

គ.៣. ផែនការរៀបចំកន្លែងអភិរក្ស ..... ១៥

គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ..... ១៦

គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ..... ១៧

គ.៦. ផែនការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ..... ១៨

គ.៧. ផែនការបង្កើតមុខរបរ ..... ១៨

គ.៨. ផែនការពង្រឹងសម្ថតភាពគណៈកម្មការសហគមន៍នេសាទ ........ ២១
គ.៩. ផែនការផ្សព្វផ្សាយពិច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ២១
គ.១០. ផែនការសាងសង់ស្នាក់ការ ........ ២២
គ.១១. ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលរួមប្រជុំផ្សេងៗ ........ ២៣
ឃ. យុទ្ធសាស្ត្រ ........ ២៣

## ៦. ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធៈ តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៨ ដល់ ២០២១

ឧបសម្ព័ន្ធៈ តារាងកម្មវិធីការងារ ឆ្នាំ២០១៨ ដល់ ២០២១

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ពៅវើយសែនជ័យ

## ១. ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផល បានធ្វើកំណែទម្រង់ ដើម្បីឲ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ ដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផល នៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌ តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើអោយធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។

សហគមន៍នេសាទ**ពៅវើយសែនជ័យ** ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងទទួលបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបជំនាញជលផលនិងកិច្ចសហការពីអាជ្ញាធរដែនដី។ សហគមន៍នេសាទ**ពៅវើយសែនជ័យ** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧។

សហគមន៍នេសាទ**ពៅវើយសែនជ័យ** មានទីតាំងស្ថិតនៅក្នុងភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានសមាជិកសរុបចំនួន៣៣៨៦នាក់ ស្រីចំនួន៧៩៨នាក់ និងមានគណៈកម្មការចំនួន០៧នាក់ ស្រី០០នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន ៤៩៦គ្រួសារ។

កន្លងមកកន្លែងនេសាទសហគមន៍**ពៅវើយសែនជ័យ** បានដំណើរការសកម្មភាពសំខាន់ៗដូចជា៖

- ដឹកនាំប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អាជ្ញាធរភូមិ ឃុំ សម្តកិច្ចរដ្ឋបាលជលផល និងអ្នកពាក់ព័ន្ធ ដើម្បីរៀបចំកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍។
- ផ្សព្វផ្សាយអំពីលិខិតបទដ្ឋានពាក់ព័ន្ធ ដល់គណៈកម្មការសហគមន៍នេសាទ និងសមាជិកសហគមន៍នេសាទ ព្រមទាំងអ្នកចូល ដែលបានមកប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍។
- ចុះល្បាត ប្រជុំប្រចាំខែ និងផ្សព្វផ្សាយពីច្បាប់ជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងកន្លែងនេសាទសហគមន៍។
- សហការជាមួយស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធ ក្នុងការទប់ស្កាត់បទល្មើសនេសាទ ដែលកើតមានក្នុងកន្លែងនេសាទសហគមន៍។
- ផ្សព្វផ្សាយអំពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ និងពាក្យសុំចូលជាសមាជិកសហគមន៍នេសាទដោយស្ម័គ្រចិត្ត ដោយមានការបង់ប្រាក់សមាជិកភាព របស់សមាជិកសហគមន៍នេសាទ។
- រៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផល។
- ផ្តល់ប្រាក់កម្ចីដល់សមាជិកសហគមន៍នេសាទក្រីក្រចំនួន០៧គ្រួសារ ដើម្បីធ្វើទុនប្រកបមុខរបរចិញ្ចឹមជីវិត។

## ២. អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ច

### ក. ប្រជាពលរដ្ឋ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន៩០៨នាក់ ប្រុស៤៥១នាក់ ស្រី៤៥៧នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន៩០៨នាក់ ខ្មែរឥស្លាមចំនួន០០នាក់ និងអនិកជនវៀតណាមចំនួន០០នាក់។
- ចំនួនស្ត្រីមេម៉ាយសរុបក្នុងសហគមន៍នេសាទមាន៣២នាក់
- ចំនួនជនពិការសរុបក្នុងសហគមន៍នេសាទមាន ០៦នាក់ ប្រុស ០៤នាក់ ស្រី ០២នាក់
- ចំនួនចាស់ជរាសរុបក្នុងសហគមន៍នេសាទមាន ០៥នាក់ ប្រុស ០១នាក់ ស្រី ០៤នាក់
- ចំនួនកុមារកំព្រាសរុបក្នុងសហគមន៍នេសាទមាន ០១នាក់ ប្រុស ០១នាក់ ស្រី ០០នាក់

- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃសរុបក្នុងសហគមន៍នេសាទមាន ០០នាក់ ប្រុស ០០នាក់ ស្រី ០០នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់

- អ្នកមិនចេះអក្សរមានចំនួន ៤០៩នាក់ ប្រុស ២០១នាក់ ស្រី ២០៨នាក់
- កម្រិតថ្នាក់បឋមសិក្សាមានចំនួន ១២៤នាក់ ប្រុស ៦៩នាក់ ស្រី ៥៥នាក់
- កម្រិតថ្នាក់មធ្យមសិក្សាមានចំនួន ៥០នាក់ ប្រុស ៣១នាក់ ស្រី ១៩នាក់
- កម្រិតថ្នាក់ឧត្តមសិក្សាមានចំនួន ០០នាក់ ប្រុស ០០នាក់ ស្រី ០០នាក់។

**ខ. មុខរបរ**

តាមរបាយការណ៍ និងឯកសារឃុំ បានបញ្ជាក់ថានៅក្នុងសហគមន៍នេសាទ**ពោធិ៍ជ័យសែនជ័យ** មានប្រជាពលរដ្ឋសរុបចំនួន៩០៨គ្រួសារ ដែលពឹងផ្អែកលើការនេសាទ ការចិញ្ចឹមត្រី រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំ ដូចជាការកែច្នៃផលនេសាទ ផ្តល់ចំណីត្រី និងលក់ដូរជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិត ដល់សមាជិកសហគមន៍នេសាទជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍នេសាទជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមក រដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍ បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ព្រមទាំងការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានភាពរីកចំរើន។ បច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទ**ពោធិ៍ជ័យសែនជ័យ** ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗដូចជា៖

**ខ.១. អ្នកដែលមានមុខរបរនេសាទ**

- ធ្វើនេសាទមានចំនួន ២២១គ្រួសារ
- ធ្វើវារីវប្បកម្មមានចំនួន ១២គ្រួសារ
- ប្រមូលទិញផលនេសាទចំនួន ០២គ្រួសារ
- អ្នកកែច្នៃផលត្រី និងនេសាទដូចជា៖ ធ្វើផ្អក ប្រហុក និងត្រីឆ្អើរ មានចំនួន ០១គ្រួសារ។

**ខ.២. អ្នកដែលមានមុខរបរធ្វើអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ**

- អ្នកលក់ដូរមានចំនួន ០៥គ្រួសារ
- ដាំបន្លែមានចំនួន ០២គ្រួសារ។

**៣, កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ**

**ក. ទីតាំង**

កន្លែងសហគមន៍នេសាទ**ពោធិ៍ជ័យសែនជ័យ** មានទីតាំងស្ថិតក្នុងភូមិពោធិ៍ជ័យ ជាដែននេសាទសាធារណៈរបស់រដ្ឋដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ៦ និងជាដែននេសាទទឹកសាបក្នុងខេត្តកំពង់ធំ ។

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** មានទំហំ ២.៦៧៥ហិកតា ហើយមានព្រៃកចំនួន០៨ នាទីព្រៃលិចទឹកចំនួន២៦កន្លែង ត្រពាំងចំនួន១០ ស្ទឹងចំនួន០១ អូរចំនួន០១។ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨។

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** មានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ទល់នឹងឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប
- ខាងត្បូង ទល់នឹងឃុំសំបូរ ស្រុកស្ទោង ខេត្តកំពង់ធំ
- ខាងកើត ទល់នឹងឃុំអន្សាក្រង ស្រុកស្ទោង ខេត្តកំពង់ធំ
- ខាងលិច ជាប់នឹងព្រំប្រទល់ខេត្តពោធិ៍សាត់។

## ខ. ដែននេសាទ

កន្លែងសហគមន៍នេសាទ**ពៅវើយសែនជ័យ** មានវិសាលភាពនៅក្នុងបឹងទន្លេសាប ដែលគ្របដណ្ដប់លើកន្លែងនេសាទ ព្រែក ត្រពាំង និងស្ទឹងសំខាន់ៗមួយចំនួនដូចជា៖

### ខ.១. ព្រែក

| ល.រ | ឈ្មោះព្រែក | ប្រវែងគីឡូម៉ែត្រ | រដូវនេសាទ |
|---|---|---|---|
| ០១ | កំពឹងគ្រឡាច | ២ | ខែមករា ដល់ ខែធ្នូ |
| ០២ | បឹងធីពោ | 0.៤ | ខែមករា ដល់ ខែធ្នូ |
| ០៣ | ខ្វែងសណ្ដាន់ | ៣ | ខែមករា ដល់ ខែធ្នូ |
| ០៤ | ដូសនុយ | 0.៥ | ខែមករា ដល់ ខែធ្នូ |
| ០៥ | ខ្វែកតាសូ | ១.៤៣ | ខែមករា ដល់ ខែធ្នូ |
| ០៦ | កោះគ្របបាយ | 0.១ | ខែមករា ដល់ ខែធ្នូ |
| ០៧ | កប់ភ្លុក | 0.១ | ខែមករា ដល់ ខែធ្នូ |
| ០៨ | ទទឹងថ្ងៃ | ១ | ខែមករា ដល់ ខែធ្នូ |

### ខ.២. ត្រពាំង

| ល.រ | ឈ្មោះត្រពាំង | ប្រវែងហិកតា | រដូវនេសាទ |
|---|---|---|---|
| ០១ | អាតុង | 0.0៩ | ខែមករា ដល់ ខែធ្នូ |
| ០២ | យាយកេះ | 0.១៦ | ខែមករា ដល់ ខែធ្នូ |
| ០៣ | ទទឹងថ្ងៃ | 0.0៦ | ខែមករា ដល់ ខែធ្នូ |
| ០៤ | សែងមង | 0.0៤ | ខែមករា ដល់ ខែធ្នូ |
| ០៥ | គាស់អណ្ដើក | 0.0២ | ខែមករា ដល់ ខែធ្នូ |
| ០៦ | អណ្ដែតជាប់ | 0.២ | ខែមករា ដល់ ខែធ្នូ |
| ០៧ | ត្រពាំងបឹងក្រម៉ោល | ៧ | ខែមករា ដល់ ខែធ្នូ |
| ០៨ | ត្រពាំងបឹងកូនខ្វែក | 0.0៤ | ខែមករា ដល់ ខែធ្នូ |
| ០៩ | ត្រពាំងបឹងបែកជើង | | ខែមករា ដល់ ខែធ្នូ |
| ១០ | ត្រពាំងបឹងព្រះត្រពាំង | | ខែមករា ដល់ ខែធ្នូ |

### ខ.៣. ស្ទឹង និង អូរ

| ល.រ | ឈ្មោះ | ប្រវែង | រដូវនេសាទ |
|---|---|---|---|
| ០១ | ស្ទឹងពៅវើយ | ១៥០០ ម៉ែត្រ | ខែមករា ដល់ ខែធ្នូ |
| ០២ | អូរជំណាក់ស្មោញ | ៤.៥ ហិកតា | ខែមករា ដល់ ខែធ្នូ |

កន្លែងនេសាទសហគមន៍**ពៅវើយសែនជ័យ** បានផ្ដល់នូវលក្ខណៈងាយស្រួល ទៅដល់ការរស់នៅ និងការធ្វើនេសាទក៏ដូចអ្នកមកពីខាងក្រៅសហគមន៍ ជាពិសេសកន្លែងនេសាទសហគមន៍បានផ្ដល់ជាជម្រកដ៏ល្អក្នុងការរស់នៅ របស់ពពួកវារីសត្វ រុក្ខជាតិ ហើយវាក៏បានផ្ដល់ចំណី និងជម្រកពងកូនសម្រាប់មច្ឆា សត្វស្លាប និងសត្វល្មូនគ្រប់ប្រភេទៗ

## គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០២កន្លែង ដែលជាកន្លែងមានសក្តានុពល សម្រាប់អភិរក្សត្រីមេពូជ។ កន្លែងអភិរក្សត្រូវបានធ្វើការគ្រប់គ្រងដោយសហគមន៍នេសាទ កន្លែងអភិរក្សត្រីមេពូជ ទាំងនេះមានដូចខាងក្រោម៖

| ល.រ | ឈ្មោះតំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស | ទំហំជា ហត | ប្រវែង |
|---|---|---|---|
| ០១ | អន្លង់ខ្វែងតាសូ | ៩.២ | ប=១៤៣០ម X ទ=៨០ម |
| ០២ | កន្លែងអភិរក្សព្រៃលិចទឹក កោះកូនចិន | ៣០៩.៣០ | |

## ឃ. ធនធានជលផល

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍**ពោធិ៍ជ័យសែនជ័យ** បានឱ្យដឹងថាពេលបច្ចុប្បន្ន ធនធានជលផល បានថយចុះជាពិសេសក្នុងឆ្នាំ២០១៥ ដោយសារមានការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យបឹង ព្រែក រីងរាក់ ហើយធ្វើឲ្យប្រភេទត្រីមេពូជ ត្រូវបាននេសាទយកស្ទើរតែទាំងអស់។

### ឃ.១. ប្រភេទត្រី

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** មានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកែះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីគ្រំ ត្រីចិន ត្រីឆ្ពិន ត្រីកន្ត្រប់ ត្រីប្រម៉ា ត្រីគ្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទឹង ត្រីខ្ជា ត្រីរ៉ស់ ត្រីឆ្ដោ ត្រីអណ្តែង ត្រីឆ្ពួញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្កោក ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំភ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្ងៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីស្រកាក្តាម ត្រីកំភ្លៀវ ត្រីខ្មាន់ ត្រីគ្រុំ ត្រីដៀប ត្រីចង្វាមូល ត្រីក្លាំងហាយ ត្រីក្អែក ត្រីលិញ។ល។

### ឃ.២. ប្រភេទវារីសត្វ

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** មានប្រភេទវារីសត្វដូចជា ក្តាម ខ្យង ខ្ចៅ គ្រំ លៀស អណ្តើក កន្ធាយ ពស់ កង្កែប ហ៊ីង គីង្គក់ អន្ទង់ ក្តាមទូក កន្ធេះឡង់ ក្រពើត្រី អន្សង់ កេ សត្វស្វាក្រុះ សំពោច ។ល។

### ឃ.៣. ប្រភេទបក្សី

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** មានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វគ្រៀល សត្វទោម សត្វទុង សត្វប្រវឹក សត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វទុង សត្វស្មោញ សត្វសេក សត្វលលក សត្វចាប សត្វក្រយង សត្វនាលខ្យង សត្វក្រដក់ សត្វក្រសា សត្វកំពីងជួង។ល។

### ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** មានប្រភេទរុក្ខជាតិព្រៃលិចទឹកនិងវារីរុក្ខជាតិដូចជា៖ដើមរាំងទឹក ដើមតាអូរ ដើមអញ្ចាញ ដើមថ្វាន់ ដើមកន្សែង ដើមបន្លាយូន ដើមស្វាចទឹក ដើមកណ្តាប់ចង្អេរ ដើមរំដេញ ដើមបន្លាស្អិត ។ល។

## ៤. ការធ្វើនេសាទ

ការធ្វើនេសាទជាមុខរបរចាំបាច់សម្រាប់ការចិញ្ចឹមជីវិតរបស់សមាជិកសហគន៍នេសាទ**ពោធិ៍ជ័យសែនជ័យ** និងផលិតផលត្រីត្រូវបានធ្វើអាជីវកម្មក្នុងតំបន់ផ្ទាល់ដើម្បីរកចំណូល។ ពេលបច្ចុប្បន្ន ប្រជាពលរដ្ឋទាំងអស់ក្នុងសហគមន៍នេះបានផ្តោតលើការនេសាទ ដោយបានប្រើប្រាស់ឧបករណ៍ជាលក្ខណៈគ្រួសារក្នុងការទាញយកផលនេសាទ ប៉ុន្តែការនេសាទរបស់សមាជិកសហគមន៍ និងអ្នកខាងក្រៅត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ជាពិសេសផែនការគ្រប់គ្រងរបស់សហគមន៍នេសាទដែលបានរៀបចំសម្រាប់ឆ្នាំ២០១៨ដល់ឆ្នាំ២០២០។

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៤៦៨នាក់   ស្រីមានចំនួន ១៩២នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍មានចំនួន ៥៨០នាក់ ស្រីមានចំនួន ២០០នាក់
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកសហគមន៍ មានប្រហែល៨៧០នាក់ ស្រី៣៧០នាក់ ក្នុង១ឆ្នាំ។

### ខ. ឧបករណ៍នេសាទ

នៅរដូវបើកនេសាទប្រជាជននៅក្នុងសហគមន៍នេសាទ**ពៅទើយសែនជ័យ** និងអ្នកខាងក្រៅតែងតែមកធ្វើការនេសាទដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារ ដូចជា លប មង សន្ទូច លបព្រៀង ទ្បើ លាន់ និងជុច។ សមាជិកនិងគណៈកម្មការសហគមន៍នេសាទ**ពៅទើយសែនជ័យ** បានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង សមាជិក និងគណៈកម្មការសហគមន៍នេសាទ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍ និងអ្នកនេសាទខាងក្រៅលើប្រភេទឧបករណ៍នេសាទ ដែលហាមឃាត់ដូចជា ឧបករណ៍ឆក់ត្រី អ៊ុយស្បៃមុង ។ល។

**ឧបករណ៍នេសាទ ទូកនិងកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជា៖**

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ=៧០ម | ៣៩០នាក់x ១០ | ២.៥សម X ១.៥ម X ១៥០០ម | ខែកក្កដាដល់ ខែមេសា |
| ០២ | សន្ទូចរនង | ១សាង | ៤០នាក់ x ១០០ | ៤០០ផ្លែ លេខ១១-១៣ | ខែវិច្ឆិកា ដល់ ខែមករា |
| ០៣ | លបទល់ | គ្រឿង | ៥នាក់x ២០ | ០,៦ម X ១,២ម X ៣សម | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ០៤ | ទ្បើ | គ្រឿង | ៥នាក់x ៣០ | ០,៣ម X ០,៧ម X ២,៥សម | ខែកញ្ញា ដល់ ខែធ្នូ |
| ០៥ | លាន់ | គ្រឿង | ១០នាក់x ៣០ | ០,៥សម - ១០សម X ១,៥ម | ខែកក្កដា ដល់ ខែមករា |
| ០៦ | អួន | វង់=១០០ម | ១០នាក់/១០០ម | ២,៥សម X ៤ម X ១០០ម | ខែមករា ដល់ ខែមេសា |
| ០៧ | សំណាញ់ | វង់ | ១៥នាក់ | ៣សម X ៦ម | ខែវិច្ឆិកា ដល់ ខែធ្នូ |
| ០៨ | លបលួង | គ្រឿង | ១០នាក់x ៣០ | ០,៣ម X ០,៥ម X ៣សម | ខែតុលា ដល់ ខែធ្នូ |
| ០៩ | កន្ទុំ | គ្រឿង | ២០នាក់x ១០០ | ១ម X ១៥សម | ខែសីហា ដល់ខែតុលា |
| ១០ | លបត្រីកញ្ចុះ | គ្រឿង | ១៥នាក់x ៣ | ០,៦ម X ១,២ម X ១.៥សម | ខែកក្កដា ដល់ ខែធ្នូ |
| ១១ | កំប្លោក | | ២០នាក់ | ១០០ម X ៥០ម | ខែមករា ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន (គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ១០០ | ៣០០ - ១តោន | ៦ ដល់ ១៨ |
| កាណូតម៉ាស៊ីនតូច | ៦០ | ៣០០ - ៥០០ | ៦ ដល់ ១២ |
| ទូកអុំ ឬ ទូកចែវ | ៣០ | ២០០ | |

ឧបករណ៍នេសាទ ទូក និងកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ=៧០ម | ៣៩០នាក់X ១០ | ២.៥សម X ១.៥ម X ១៥០០ម | ខែកក្កដាដល់ ខែមេសា |
| ០២ | សន្ទូចរនង | ១សាង | ៨០នាក់ X ១០០ | ៨០០ផ្លែ លេខ១១-១៣ | ខែវិច្ឆិកា ដល់ ខែមករា |
| ០៣ | លបទល់ | គ្រឿង | ៥នាក់X ២០ | ០,៦ម X ១,២ម X ៣សម | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ០៤ | ទ្បើ | គ្រឿង | ៥នាក់X ៣០ | ០,៣ម X ០,៧ម X ២,៥សម | ខែកញ្ញា ដល់ ខែធ្នូ |
| ០៥ | លាន់ | គ្រឿង | ១០នាក់X ៣០ | ០,៥សម - ១០សម X ១,៥ម | ខែកក្កដា ដល់ ខែមករា |
| ០៦ | អួន | វង់=១០០ម | ១០នាក់/១០០ម | ២,៥សម X ៤ម X ១០០ម | ខែមករា ដល់ ខែមេសា |
| ០៧ | សំណាញ់ | វង់ | ១៥នាក់ | ៣សម X ៦ម | ខែវិច្ឆិកា ដល់ ខែធ្នូ |
| ០៨ | លបលួង | គ្រឿង | ១០នាក់X ៣០ | ០,៣ម X ០,៥ម X ៣សម | ខែតុលា ដល់ ខែធ្នូ |
| ០៩ | កន្ទ្រុំ | គ្រឿង | ២០នាក់X ១០០ | ១ម X ១៥សម | ខែសីហា ដល់ខែតុលា |
| ១០ | លបត្រីកញ្ចុះ | គ្រឿង | ១៥នាក់X ៣ | ០,៦ម X ១,២ម X ១.៥សម | ខែកក្កដា ដល់ ខែធ្នូ |
| ១១ | កំប្លោក | | ២០នាក់ | ១០០ម X ៥០ម | ខែមករា ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ៧០ | ៣០០ - ១តោន | ៦ ដល់ ១៨ |
| កាណូតម៉ាស៊ីនធំតូច | ៣០ | ៣០០ - ៥០០ | ៦ ដល់ ១២ |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ | ១៥៣នាក់X ៣០ | ២.៥សម X១.៥មX១៥០០ម | ខែកក្កដាដល់ ខែមេសា |
| ០២ | លបទល់ | គ្រឿង | ៥នាក់X ២០ | ០,៦ម X ១,២ម X ៣សម | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ០៣ | ទ្បើ | គ្រឿង | ៣នាក់X ១០០ | ០,៣ម X ០,៧ម X ២,៥សម | ខែកញ្ញា ដល់ ខែធ្នូ |
| ០៤ | លាន់ | គ្រឿង | ១០នាក់X ៣០ | ០,៥សម - ១០សម X ១,៥ម | ខែកក្កដា ដល់ ខែមករា |
| ០៥ | អួន | វង់ | ៥វង់/៥០០ម | ២,៥សម X ៤ម X ៥០០ម | ខែមករា ដល់ ខែមេសា |
| ០៦ | សំណាញ់ | វង់ | ១០ | ៣សម X ៦ម | ខែវិច្ឆិកា ដល់ ខែធ្នូ |
| ០៧ | លបលួង | គ្រឿង | ១០នាក់X ៣០ | ០,៣ម X ០,៥ម X ៣សម | ខែតុលា ដល់ ខែធ្នូ |
| ០៨ | សំរាស់ | | ៣០គ្រួ/១៥០កាធំ | ៤៥០០ម៉ែត្រ | ខែសីហា ដល់ខែតុលា |
| ០៩ | សម | គ្រឿង | ២០នាក់X ១០ | | ខែកក្កដា ដល់ ខែធ្នូ |
| ១០ | អួនព្រយ៉ុង | វង់/៥០ម | ១៥នាក់X ៥០ | ០,៦ម X ១,២ម X ១.៥សម | ខែកក្កដា ដល់ ខែធ្នូ |
| ១១ | ជុច | | ៥នាក់X ៣០ | | ខែមករា ដល់ ខែមីនា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ៧០ | ៣០០ - ១តោន | ៦ ដល់ ២២ |
| កាណូតម៉ាស៊ីនធំតូច | ៣០ | ៣០០ - ៥០០ | ៥.៥ ដល់ ១៥ |

នៅរដូវប្រាំង ជាញឹកញាប់អ្នកមកពីខាងក្រៅធ្វើដំណើរមកធ្វើនេសាទក្នុងដែននេសាទសហគមន៍ដោយមធ្យោបាយផ្សេងៗ ដូចបង្ហាញក្នុងតារាងខាងក្រោម៖

| មធ្យោបាយធ្វើដំណើរ | ចំនួន(គ្រឿង) | ចំណុះ(គក) | ផ្សេងៗ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ៤០ | ៣០០ - ១តោន | ៦ ដល់ ២២ |
| កាណូតម៉ាស៊ីនធំតូច | ៣០ | ៣០០ - ៥០០ | ៥.៥ ដល់ ១៥ |

## គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ២៧០០ | ២១៦០ | ៤,៨៦០ |
| ក្តាម ខ្យង ខ្ចៅ និងលៀស | ០០ | ១២០០ | ១២០០ |
| អន្ទង់ | ២៥០ | ៥០ | ៣០០ |
| **សរុប** | **២.៩៥០** | **៣.៤១០** | **៦.៣៦០** |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

កន្លែងនេសាទសហគមន៍**ពោធិ៍ជ័យសែនជ័យ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និង និរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនន់ នាទីព្រៃលិចទឹក ព្រៃកោងកាង និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយបានគិតគូរអំពីប្រភេទឧបករណ៍ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឲ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផល ដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទ នៅក្នុងកន្លែងនេសាទ**ពោធិ៍យសែនជ័យ** ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ឈ្មោះកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើកន្លែងនេសាទសហគមន៍ | | | |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | ផ្សេងៗ |
| ព្រែកអំពឹលត្រឡាច | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៤២នាក់ | ៤២នាក់ |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ១៥ នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ៤៥ នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២៥ នាក់ | ២៥ នាក់ |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ១០នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ៨ នាក់ | ១០នាក់ |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ១២ នាក់ | ១០នាក់ |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ១២ នាក់ | |
| | កក្កដា - កញ្ញា | កន្ទុំ | ១០០គ្រឿង ក្នុង១នាក់ | ២០ នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៧ នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ១០ នាក់ | |
| ព្រែកជីពោ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ១០ នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ២ នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ៥ នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ១២ នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ៦ នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ៨ នាក់ | |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ៣ នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២ នាក់ | |
| | កក្កដា - កញ្ញា | កន្ទុំ | ១០០គ្រឿង ក្នុង១នាក់ | ២ នាក់ | |

| | | | | | |
|---|---|---|---|---|---|
| | ធ្នូ - មីនា | ផុច | ៤០គ្រឿង ក្នុង១នាក់ | ៤ នាក់ | |
| ព្រែកខ្មែរ សណ្ដាន់ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ២០នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ៣០នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១៥ នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ៣០ នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ១០នាក់ | |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ១៥ នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ៥ នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០ នាក់ | |
| | កក្កដា - កញ្ញា | កន្ទុំ | ១០០គ្រឿង ក្នុង១នាក់ | ៣០ នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ១៥ នាក់ | |
| | ធ្នូ - មីនា | ផុច | ៤០គ្រឿង ក្នុង១នាក់ | ១០ នាក់ | |
| អូរដំណាក់ ស្មោញ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៦នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ៣នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១៥ នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០ នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ១២នាក់ | |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ៣ នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ៥ នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០ នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ១៥ នាក់ | |
| | ធ្នូ - មីនា | ផុច | ៤០គ្រឿង ក្នុង១នាក់ | ១០ នាក់ | |
| ព្រែកជូសនុយ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ១៥នាក់ | |

| | | | | | |
|---|---|---|---|---|---|
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ៦នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ២០ នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២៥ នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ១៦នាក់ | |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ៧ នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ៣ នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ៧ នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ១០ នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៥ នាក់ | |
| ព្រែក កោះគ្រប ឆាយ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ១៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ៦នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ២០ នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២៥ នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ១៦នាក់ | |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ៧ នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ៣ នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ៧ នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ១០ នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៥នាក់ | |
| ព្រែក អប់ឆ្លុក | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៣០នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១៨នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ៣០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២៥នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ១០នាក់ | |

| | | | | | |
|---|---|---|---|---|---|
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ៥នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៧នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| ព្រែក ទទឹងថ្ងៃ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥០នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ៧នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ថ្លៃ ក្នុង១នាក់ | ១៥នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២៥នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ១០នាក់ | |
| | សីហា - មករា | សំណាញ់ | ១វង់ ក្នុង១នាក់ | ៦នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ១០នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ២០នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| ត្រពាំង អាត្មុខ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ថ្លៃ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |

| | | | | | |
|---|---|---|---|---|---|
| ត្រពាំងយាយកោះ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |
| ត្រពាំងទទឹងថ្ងៃ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៣០នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |
| ត្រពាំងសែនមង | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |

| | | | | | |
|---|---|---|---|---|---|
| ត្រពាំងគាស់អណ្តើក | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |
| ត្រពាំងអណ្តោងជាប់ | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |
| ត្រពាំងបឹងក្រម៉ោល | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ចុះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |

| | | | | | |
|---|---|---|---|---|---|
| **ត្រពាំងបឹង កូនខ្មែរ** | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ជះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |
| **ត្រពាំង បែកជើង** | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ជះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |
| **ត្រពាំង បឹងព្រះត្រពាំង** | កក្កដា - កុម្ភៈ | មង | ក្រឡា= ២.៥ សម<br>ប្រវែង= ៣០០ ម | ៥នាក់ | |
| | មេសា - ឧសភា | អួន | ក្រឡា= ២.៥ សម<br>ប្រវែង= ៧០ ម | ១នាក់ | |
| | កក្កដា - មីនា | សន្ទូចរនង | ៥០០ផ្លែ ក្នុង១នាក់ | ១០នាក់ | |
| | មករា - មីនា | លបទល់ | ១០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | មេសា - មិថុនា | លបលួង | ១០គ្រឿង ក្នុង១នាក់ | ២នាក់ | |
| | មិថុនា - កក្កដា | លបត្រីកញ្ជះ | ៣សម្រាប់ | ២នាក់ | |
| | មិថុនា - ធ្នូ | លាន់ | ២០គ្រឿង ក្នុង១នាក់ | ២០នាក់ | |
| | ឧសភា - មិថុនា | អួនប្រយ៉ុង | ២០ម៉ែត្រ ក្នុង១នាក់ | ៣នាក់ | |
| | ធ្នូ - មីនា | ជុច | ៤០គ្រឿង ក្នុង១នាក់ | ៣នាក់ | |

## គ.២. ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ ពីព្រោះថាការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទ នៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថាដែននេសាទនៅក្នុងសហគមន៍នេសាទពោធិ៍ជ័យសែនជ័យ មានសភាពប្រែប្រួលខ្លះ ដែលបណ្តាល មកពីកត្តាមនុស្ស និងធម្មជាតិ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឱ្យសំបូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

**ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖**

| ឈ្មោះដែននេសាទ | ទំហំ ហត | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| អន្លង់ខ្វែងតាសូ | ៩.៧២ | ២ហត | ធ្វើការសិក្សា | ខែឧសភា ២០១៨ | ខែឧសភា ២០២០ |
| កោះកូនចិន | ៣០៩.២៩ | ០.៧៧ | ធ្វើការសិក្សា | ខែឧសភា ២០១៨ | ខែឧសភា ២០២០ |

## គ.៣. ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទ**ពោធិ៍ជ័យសែនជ័យ** បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០៧កន្លែង គឺពាមកំពីងត្រឡាច ពាមអន្លង់តាសៅ ព្រៃពាមបាង ព្រៃសាន់ក្រង ព្រៃត្រពាំងអាតែ ព្រៃបាយាប ព្រៃកំពីងត្រឡាច ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ។ ដូចនេះកន្លែងអភិរក្ស បានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទ**ពោធិ៍ជ័យសែនជ័យ** ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរនេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

